ក្រុមហ៊ុនធានារ៉ាប់រង កម្ពុឡុនប៉ាក

CAMPU LONPAC INSURANCE 柬埔寨大众伦平保险

# យើងខ្ញុំធានារ៉ាប់រងលោកអ្នក
# ក្នុងប្រទេសកម្ពុជា

កិច្ចសន្យាធានារ៉ាប់រងលើគេហដ្ឋាន

ប្រសិនបើលោកអ្នកមិនពេញចិត្តនឹងសេវាកម្មរបស់ក្រុមហ៊ុនយើងខ្ញុំ សូមមេត្តាសរសេរលិខិតមកក្រុមទទួលពាក្យបណ្តឹងរបស់យើងខ្ញុំ :

| | | |
|---|---|---|
| អាសយដ្ឋានទំនាក់ទំនង | : | **ក្រុមហ៊ុនធានារ៉ាប់រង កម្ពុឡុនប៉ាក ភីអិលស៊ី**<br>ជាន់ទី៧ នៃអគារកម្ពុប៊ែង<br>ផ្ទះលេខ ២៣ ផ្លូវ ១១៤<br>សង្កាត់ផ្សារថ្មី ២<br>ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>ព្រះរាជាណាចក្រកម្ពុជា<br>ប្រអប់សំបុត្រ ១៥៥៦ |
| លេខទូរស័ព្ទ | : | + ៨៥៥ ២៣ ៩៦៦ ៥៦៦ / ៩៩៨ ២០០ / ៩៨៦ ២៧៩ |
| លេខទូរសារ | : | + ៨៥៥ ២៣ ៩៨៦ ៣០៨ / ២៧៣ |
| អ៊ីម៉ែល | : | complaint@campulonpac.com.kh |
| គេហទំព័រ | : | www.campulonpac.com.kh |

**ក្នុងករណីមានឧប្បត្តិហេតុកើតឡើង**

លេខទូរសព្ទ័ប្រចាំការ២៤ម៉ោង

+ ៨៥៥ ១៦ ៨១០ ៩៩៩ / ៨២០ ៩៩៩

+ ៨៥៥ ១៧ ៧៩៩ ៩០២ / ៧៩៩ ៩០៣

អ៊ីម៉ែល : claims@campulonpac.com.kh

<u>សំគាល់:</u>

ក្នុងករណីមានវិវាទកើតឡើង ឬការខុសឆ្គងអត្ថន័យណាមួយនៅក្នុងកិច្ចសន្យាធានារ៉ាប់រងជាភាសាខ្មែរ នោះក្រុមហ៊ុនធានារ៉ាប់រងយើងខ្ញុំនឹងយកកិច្ចសន្យាធានារ៉ាប់រងជាភាសាអង់គ្លេសជាសំអាង ។
យើងខ្ញុំសូមស្នើជាពិសេសថា សូមលោកអ្នកអានកិច្ចសន្យាធានារ៉ាប់រងនេះអោយបានហ្មត់ចត់និងផ្ញើត្រឡប់មកកាន់ក្រុមហ៊ុនយើងខ្ញុំវិញភ្លាមប្រសិនបើមានភាពចាំបាច់ត្រូវកែតម្រូវ ។

## កិច្ចសន្យាធានារ៉ាប់រងលើគេហដ្ឋាន

**ដោយហេតុថា** បុគ្គលដែលត្រូវបានធានារ៉ាប់រង ដែលតាមរយៈទម្រង់បែបបទស្នើសុំការធានារ៉ាប់រង និងសេចក្តីប្រកាសអះអាង ដែលនឹងត្រូវក្លាយជាមូលដ្ឋានគ្រឹះ និងជាធាតុសំខាន់នៃកិច្ចសន្យានេះ បានស្នើសុំពីក្រុមហ៊ុនសម្រាប់ការធានារ៉ាប់រង ដែលមានដូចខាងក្រោមនេះ និងដោយហេតុថាបានបង់ជូនក្រុមហ៊ុនសម្រាប់បុព្វលាភធានារ៉ាប់រងដំបូង ។

ដោយហេតុនេះកិច្ចសន្យាធានារ៉ាប់រងនេះផ្តល់នូវសក្ខីកម្មដែលបញ្ជាក់ថា ក្នុងករណីមានហេតុការណ៍កើតឡើងក្នុងអំឡុងពេលនៃ ការធានារ៉ាប់រង និងដោយផ្អែកលើដែនកំណត់នៃករណីលើកលែង និងលក្ខខណ្ឌដែលមានចែងនៅក្នុងកិច្ចសន្យានេះ ឬនៅក្នុងបដិលេខ (តទៅត្រូវបានចាត់ទុកថាជាលក្ខខណ្ឌនៃកិច្ចសន្យានេះ): ក្រុមហ៊ុននឹងធ្វើសំណង ឬតាមជម្រើសដោយធ្វើការផ្លាស់ប្តូរអោយដូចដើមវិញ ឬធ្វើសំណងលើការជួសជុលការខូចខាតជូនបុគ្គលដែលត្រូវបានធានារ៉ាប់រង ចំពោះការបាត់បង់ ឬការខូចខាតលើទ្រព្យសម្បត្តិដែលត្រូវបានធានារ៉ាប់រង ដែលបង្កឡើងដោយហានិភ័យណាមួយដូចខាងក្រោមៈ

១. អគ្គិភ័យ រន្ទះ ផ្គររន្ទះ អគ្គិភ័យក្រោមដី

២. ការផ្ទុះនានា

៣. ការធ្លាក់យន្តហោះ និងឧបករណ៍ផ្សេងៗទៀតដែលស្ថិតក្នុងលំហអាកាស និង/ឬបំណែកណាមួយដែលធ្លាក់ពីលំហអាកាស

៤. ការបុកប៉ះទង្គិចផ្នែកណាមួយនៃអគារ ដែលបង្កឡើងដោយយានយន្តណាមួយ ឬសត្វពាហនៈដែលមិនមែនជាកម្មសិទ្ធិ ឬស្ថិតក្រោមការគ្រប់គ្រងរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង ឬសមាជិកគ្រួសារណាមួយរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង

៥. ការបែកធ្លាយ និងការហៀរចេញនៃទឹកពីធុងដាក់ទឹក ឧបករណ៍ ឬបំពង់បង្ហូរទឹក លើកលែងតែការបំផ្លាញ ឬការខូចខាតកើតឡើងក្នុងខណៈពេលដែលលំនៅដ្ឋានឯកជនរបស់លោកអ្នក ត្រូវបានទុកទំនេរចោលដោយគ្មានការថែទាំ

៦. ខ្យល់ព្យុះ ព្យុះកំបុតត្បូង ព្យុះសង្ឃរា ព្យុះភ្លៀង

៧. រញ្ជួយផែនដី បន្ទុះភ្នំភ្លើង ។

**ខចែងស្តីពីចំនួនទឹកប្រាក់មិនធ្វើសំណង**

នៅពេលដែលមានការបាត់បង់ ឬខូចខាតចំពោះអគារលំនៅដ្ឋានឯកជន និង/ឬទ្រព្យសម្បត្តិ ដែលបង្កឡើងដោយផ្ទាល់ពីហានិភ័យណាមួយនោះការទទួលខុសត្រូវរបស់ក្រុមហ៊ុននឹងត្រូវបានកំណត់តាមអត្រាសមាមាត្រនៃចំនួនទឹកប្រាក់តាមរយៈការបាត់បង់ ឬការខូចខាតដែលលើសពីចំនួនទឹកប្រាក់ដែលបានបញ្ជាក់ក្នុងតារាងឧបសម្ព័ន្ធ ។ ខចែងនេះនឹងអនុវត្តដាច់ដោយឡែក ចំពោះ :

(i) ក្នុងគោលបំណងនេះអគារនីមួយៗ ដែលត្រូវបានដាក់ធានាស្ថិតនៅក្នុងទីតាំងដូចគ្នា ដូចដែលបានបញ្ជាក់នៅក្នុងតារាងឧបសម្ព័ន្ធ ត្រូវបានចាត់ទុកថាជាអគារតែមួយ

(ii) គ្រោះថ្នាក់នីមួយៗដែលបណ្តាលអោយមានការបាត់បង់ ឬការខូចខាត និងសម្រាប់គោលបំណងនេះ គ្រោះថ្នាក់នោះមិនត្រូវបានចាត់ទុកថាបានបញ្ចប់នោះទេ រហូតដល់៧ថ្ងៃបន្តបន្ទាប់គ្នាដោយមិនជាប់ទាក់ទងនឹងហានិភ័យដែលពាក់ព័ន្ធ ហើយក្នុងករណីនេះខចែងនេះនឹងត្រូវអនុវត្តសារជាថ្មី ។

## ផ្នែកទី១_អគារ

ក្រុមហ៊ុននឹងធ្វើសំណងជូនបុគ្គលដែលត្រូវបានធានារ៉ាប់រងលើការបាត់បង់ ឬការខូចខាតចំពោះលំនៅដ្ឋានឯកជន ដែលបណ្តាលមកពីហានិភ័យណាមួយដែលបានបញ្ជាក់ជូនខាងលើ ដោយរាប់បញ្ចូលទាំងការិយាល័យដែលស្ថិតនៅក្នុងផ្ទះ ក្រោល ឬរោង យានដ្ឋាន និងអគារផ្សេងៗទៀតដែលត្រូវបានប្រើប្រាស់ និងស្ថិតនៅក្នុងបរិវេណដូចគ្នា ព្រមទាំងសម្ភារដែលបំពាក់ជាប់នឹងអគារ និងជញ្ជាំង ក្លោងទ្វារ និងរបងព័ទ្ធជុំវិញ និងផ្នែកដែលពាក់ព័ន្ធផ្សេងៗទៀត ។

ក្នុងករណីដែលកិច្ចសន្យាត្រូវបានធ្វើឡើងដើម្បីធានារ៉ាប់រងលើអគារផ្ទះល្វែង ដោយយោងតាមកិច្ចសន្យានេះពាក្យថា " លំនៅដ្ឋានឯកជន" នឹងត្រូវបានចាត់ទុកថាជា ផ្ទះល្វែង ឬអគារស្នាក់នៅឯកជន ។

## ផ្នែកទី២_ទ្រព្យសម្បត្តិ

**(ក) ការបាត់បង់ ឬការខូចខាតចំពោះទ្រព្យសម្បត្តិ**

ក្រុមហ៊ុននឹងធ្វើសំណងជូនបុគ្គលដែលត្រូវបានធានារ៉ាប់រងលើការបាត់បង់ ឬការខូចខាតចំពោះទ្រព្យសម្បត្តិ ឬសម្ភារដែលបណ្តាលមកពីហានិភ័យណាមួយដែលបានបញ្ជាក់ជូនខាងលើដែលរួមមាន : ទំនិញរបស់ម្ចាស់ផ្ទះ និងទ្រព្យសម្បត្តិផ្ទាល់ខ្លួនគ្រប់ប្រភេទ (លើកលែងតែត្រូវបានបញ្ជាក់ផ្សេងពីនេះ) ដែលជាកម្មសិទ្ធិរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង ឬសមាជិកគ្រួសារណាមួយដែលស្នាក់នៅធម្មតាជាមួយបុគ្គលដែលត្រូវបានធានារ៉ាប់រង ក្នុងលំនៅដ្ឋានឯកជនដោយ

រួមមាន : លំនៅដ្ឋានឯកជន ផ្ទះល្វែង ឬអគារស្នាក់នៅ និងការិយាល័យក្នុងផ្ទះ រោង ឬក្រោល យានដ្ឋាន និងអគារផ្សេងៗទៀតដែលត្រូវបានប្រើប្រាស់ និងស្ថិតនៅក្នុងបរិវេណដូចគ្នាដូចដែលបានបញ្ជាក់នៅក្នុងតារាងឧបសម្ព័ន្ធ ។

ដោយហេតុថា :

(ក) គ្មានផ្នែកណាមួយនៃរចនាសម្ព័ន្ធអគារ ឬពិតាន ក្រដាសបិទជញ្ជាំង ឬសម្ភារស្រដៀងគ្នានេះត្រូវបានធានារ៉ាប់រង ស្ថិតក្រោមផ្នែកនេះឡើយ

(ខ) គ្មានវត្ថុណាមួយ (គ្រឿងសង្ហារិម ព្យ៉ាណូ ឧបករណ៍ភ្លេង ប្រដាប់ប្រើប្រាស់ក្នុងផ្ទះ វិទ្យុ ទូរទស្សន៍ (ឈុត) ម៉ាស៊ីនថតសម្លេងវីឌីអូ (ឈុត) ឧបករណ៍ Hi-Fi និងឧបករណ៍ស្រដៀងគ្នាដទៃទៀត) ដែលត្រូវបានចាត់ទុកថាមានតម្លៃលើសពី ៥% នៃចំនួនទឹកប្រាក់សរុបដែលត្រូវបានធានារ៉ាប់រងលើផ្នែកទ្រព្យសម្បត្តិ ឬសម្ភារ លើកលែងតែវត្ថុទាំងនោះ ត្រូវបានប្រកាសជាពិសេសដាច់ដោយឡែក

(គ) តម្លៃសរុបនៃប្លាទីន មាស និងវត្ថុដែលធ្វើពីប្រាក់ គ្រឿងអលង្ការ និងរោមសត្វ ត្រូវបានសន្មតថាមិនត្រូវលើសពី ១/៣ នៃចំនួនទឹកប្រាក់សរុបដែលត្រូវបានធានារ៉ាប់រងលើទ្រព្យសម្បត្តិ

(ឃ) នៅក្នុងផ្នែកនេះមិនធានារ៉ាប់រងលើទ្រព្យសម្បត្តិដែលមានការធានាជាក់លាក់ លើកលែងតែមានការបញ្ជាក់ជាពិសេស ដូចជា ឯកសារកម្មសិទ្ធិ ប័ណ្ណបំណុល ប័ណ្ណប្តូរប្រាក់ ប័ណ្ណសន្យាសងប្រាក់ មូលបទានប័ត្រ ធនប័ត្រ ត្រា ឯកសារគ្រប់ប្រភេទ សាច់ប្រាក់ រូបិយប័ណ្ណ ប័ណ្ណបើកប្រាក់ពីធនាគារ កំណត់ត្រាសរសេរដោយដៃ មេដាយ និងកាក់ប្រាក់ យានយន្ត និងគ្រឿងបន្ទាប់បន្សំ ឬបសុសត្វ ។

**(ខ.) អំពើចោរកម្មដោយការប្រើកំលាំង និងហិង្សាក្នុងការចេញ ឬចូលក្នុងអគារ (ត្រូវបានអនុវត្តប្រសិនបើអំពើចោរកម្ម ត្រូវបានធានារ៉ាប់រង)**

ក្រុមហ៊ុននឹងធ្វើសំណងជូនបុគ្គលដែលត្រូវបានធានារ៉ាប់រងចំពោះការបាត់បង់ ឬការខូចខាតដែលបណ្តាលមកពីអំពើចោរកម្ម ក្នុងករណីដែលមានការប្រើកំលាំង និងហិង្សាក្នុងការចូល ឬចេញពីអគារ ។

ដោយហេតុថា លំនៅដ្ឋានឯកជនត្រូវបានទុកទំនេរដោយគ្មានអ្នករស់នៅលើសពី ៩០ថ្ងៃ បន្តបន្ទាប់គ្នា ឬអត់ក៏ដោយ នោះការធានារ៉ាប់រងនៅក្នុងផ្នែកនេះនឹងត្រូវបានបញ្ឈប់នៅក្នុងអំឡុងពេលនៃការធានារ៉ាប់រងណាមួយ ឬក្នុងអំឡុងពេលផ្សេងទៀត ដែលលំនៅដ្ឋានឯកជនអាចត្រូវបានទុកទំនេរចោលលើសពី ៩០ថ្ងៃ ដូចដែលបានបញ្ជាក់ខាងដើម ប៉ុន្តែករណីនេះ នឹងមិនអនុវត្តប្រសិនបើមានការព្រមព្រៀងផ្សេងទៀត ដែលមានបញ្ជាក់ក្នុងបដិលេខ ។

ការធានារ៉ាប់រងនៅក្នុងផ្នែកនេះមិនទទួលខុសត្រូវលើការបាត់បង់ ឬការខូចខាតចំពោះទ្រព្យសម្បត្តិដោយអំពើចោរកម្មដែលបង្កឡើងដោយអ្នកបម្រើក្នុងផ្ទះរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង ឬសមាជិកគ្រួសារ ឬសមាជិកក្នុងផ្ទះរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង ។

**(គ.) ទ្រព្យសម្បត្តិរបស់អ្នកបម្រើក្នុងផ្ទះ (ចំនួន ២៥០ដុល្លារ សម្រាប់អ្នកបម្រើម្នាក់) - (ត្រូវបានអនុវត្តប្រសិនបើផ្នែកទី ២(ខ) ត្រូវបានធានារ៉ាប់រង)**

ក្រុមហ៊ុននឹងផ្តល់សំណងតាមរយៈបុគ្គលដែលត្រូវបានធានារ៉ាប់រង សម្រាប់ការបាត់បង់ ឬការខូចខាតដែលបណ្តាលមកពីហានិភ័យដែលត្រូវបានធានារ៉ាប់រងចំពោះសម្លៀកបំពាក់ និងទ្រព្យសម្បត្តិផ្ទាល់ខ្លួន (ក្រៅពីសាច់ប្រាក់ ក្រដាសប្រាក់ ប័ណ្ណបើកប្រាក់ពីធនាគារ និងប័ណ្ណប្រៃសណីយ៍) ដែលជាកម្មសិទ្ធិរបស់អ្នកបម្រើក្នុងផ្ទះរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង ហើយជាងនេះទៀត ទ្រព្យសម្បត្តិទាំងនោះមិនត្រូវបានធានារ៉ាប់រងខណៈពេលដែលស្ថិតនៅក្នុងលំនៅដ្ឋានឯកជនព្រមទាំងស្ថិតនៅក្នុងទីតាំងដែលអ្នកបម្រើទាំងនោះស្នាក់នៅជាមួយបុគ្គលដែលត្រូវបានធានារ៉ាប់រង ឬសមាជិកគ្រួសារណាមួយរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង ។

**(ឃ.) ការខូចខាតចំពោះផ្ទាំងកញ្ចក់ (ត្រូវបានអនុវត្តប្រសិនបើផ្នែកទី ២(ខ) ត្រូវបានធានារ៉ាប់រង)**

ក្រុមហ៊ុននឹងធ្វើសំណងជូនបុគ្គលដែលត្រូវបានធានារ៉ាប់រងលើការបាត់បង់ ឬ ការខូចខាតចំពោះផ្ទាំងកញ្ចក់ដែលមិនមែនជា កញ្ចក់ឆ្លុះមុខ ដោយសារការបាក់បែកដែលស្ថិតនៅក្នុងលំនៅដ្ឋានឯកជន ។ ការទទួលខុសត្រូវរបស់ក្រុមហ៊ុននៅក្នុងផ្នែកនេះ ត្រូវបានកំណត់ត្រឹមតែ ១៥០ ដុល្លារ សម្រាប់កញ្ចក់មួយផ្ទាំងក្នុងករណីគ្រោះថ្នាក់នីមួយៗ ។

**(ង.) សំណងលើមរណភាពរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង-(ត្រូវបានអនុវត្ត ប្រសិនបើផ្នែកទី ២ (ខ) ត្រូវបានធានារ៉ាប់រង)**

ក្នុងករណីដែលបុគ្គលដែលត្រូវបានធានារ៉ាប់រង ទទួលរងរបួសបណ្តាលអោយបាត់បង់ជីវិតនៅក្នុងលំនៅដ្ឋានឯកជន ជាហេតុបណ្តាលមកពីអំពើហិង្សា និងមើលឃើញពីខាងក្រៅដែលបង្កឡើងដោយអំពើចោរកម្ម ឬអគ្គិភ័យ នោះក្រុមហ៊ុននឹងធ្វើសំណងនូវចំនួនទឹកប្រាក់ដូចដែលបានបញ្ជាក់នៅក្នុងតារាងឧបសម្ព័ន្ធ ឬ ១/២ នៃចំនួនទឹកប្រាក់សរុបលើទ្រព្យសម្បត្តិ ឬសម្ភារ ដោយយកចំនួនទឹកប្រាក់ណាមួយដែលតិចជាងគេ និងក្នុងលក្ខខណ្ឌថាមរណភាពនោះត្រូវបានកើតឡើងក្នុងរយៈពេល ៣ខែ បន្ទាប់ពីរងរបួសលើរាងកាយ ។

វាគឺជាសេចក្តីប្រកាសអះអាង និងព្រមព្រៀងថា ប្រសិនបើឈ្មោះបុគ្គលដែលត្រូវបានធានារ៉ាប់រងមានលើសពីមួយ(១) ដោយផ្អែកតាមកិច្ចសន្យាធានារ៉ាប់រងនេះ ឈ្មោះដែលត្រូវធានានីមួយៗនៅក្នុងការធានារ៉ាប់រងនោះត្រូវបានចាត់ទុកថាត្រូវបានធានារ៉ាប់រងលើរបួសដែលបណ្តាលអោយបាត់បង់ជីវិត ហើយក្រុមហ៊ុននឹងទទួលខុសត្រូវនូវចំនួនសមាមាត្រនៃសំណងដែលនឹងត្រូវបង់ជូនតែប៉ុណ្ណោះ ។

វាក៏ជាការព្រមព្រៀង និងអះអាងថា ប្រសិនបើកិច្ចសន្យាធានារ៉ាប់រងនេះត្រូវបានចេញជូនបុគ្គលដែលត្រូវបានធានារ៉ាប់រងជាក្រុមហ៊ុន នោះអត្ថប្រយោជន៍ក្នុងផ្នែកនេះត្រូវបានចាត់ទុកជាមោឃៈ លើកលែងតែបុគ្គលដែលត្រូវបានធានារ៉ាប់រងផ្តល់ឈ្មោះរបស់បុគ្គលណាមួយ ឬបុគ្គលដទៃទៀតតាមរយៈបដិលេខបន្ថែម ។

ដោយហេតុនេះ ការទទួលខុសត្រូវរបស់ក្រុមហ៊ុនស្ថិតនៅក្នុងអំឡុងពេលនៃការធានារ៉ាប់រងនីមួយៗត្រូវបានកំណត់ត្រឹមចំនួនទឹកប្រាក់ដែលបានបញ្ជាក់នៅក្នុងតារាងឧបសម្ព័ន្ធ ឬ ១/២ នៃចំនួនទឹកប្រាក់សរុបលើទ្រព្យសម្បត្តិ ឬសម្ភារដូចដែលបានបញ្ជាក់ជូនខាងលើ ។

## ផ្នែកទី៣_ការធានារ៉ាប់រងផ្សេងទៀត

**(ក.) ការទទួលខុសត្រូវជាសាធារណៈ**

ក្រុមហ៊ុននឹងធ្វើសំណងជូនបុគ្គលដែលត្រូវបានធានារ៉ាប់រងនូវចំនួនទឹកប្រាក់ដែលបានដាក់ធានា ដែលបុគ្គលត្រូវបានធានារ៉ាប់រងនោះត្រូវទទួលខុសត្រូវស្របច្បាប់ :

(ក) **ត្រូវបានអនុវត្តនៅពេលដែលផ្នែកទី១-អគារត្រូវបានធ្វើសំណង**

ក្នុងនាមជាម្ចាស់លំនៅដ្ឋានឯកជន នៅពេលមានឧបទ្ទវហេតុកើតឡើងដែលបណ្តាលមកពីអទិបុណភាព (ភាពខ្វះចន្លោះ) ក្នុងអគារនៃលំនៅដ្ឋានឯកជន ឬទ្រព្យសម្បត្តិរបស់ម្ចាស់អគារ ឬក្នុងជញ្ជាំង ក្លោងទ្វារ របង និង ដើមឈើដែលស្ថិតនៅក្នុងទីតាំងជាមួយនឹងលំនៅដ្ឋានឯកជននោះ ។

(ខ) **ត្រូវបានអនុវត្តនៅពេលដែលផ្នែកទី២-ទ្រព្យសម្បត្តិត្រូវបានធ្វើសំណង**

ក្នុងនាមជាម្ចាស់ផ្ទះដែលស្នាក់នៅក្នុងលំនៅដ្ឋានឯកជន នៅពេលមានឧបទ្ទវហេតុកើតឡើងនៅក្នុង ឬជុំវិញលំនៅដ្ឋានឯកជនដែលកើតឡើងក្នុងអំឡុងពេលនៃការធានារ៉ាប់រង និងបណ្តាលអោយ :

១. របួសលើរាងកាយចំពោះបុគ្គលណាមួយ ដែលមិនមែនជាសមាជិកគ្រួសាររបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង ឬម្ចាស់ផ្ទះ ឬក្នុងខណៈពេលដែលរបួសមានជាប់ទាក់ទងនឹងការផ្តល់សេវាកម្មរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង ។

២. ការខូចខាតចំពោះទ្រព្យសម្បត្តិ ដែលមិនមែនជាកម្មសិទ្ធិ ឬស្ថិតក្នុងការគ្រប់គ្រង ឬការទទួលខុសត្រូវរបស់បុគ្គល ដែលត្រូវបានធានារ៉ាប់រង ឬ សមាជិកគ្រួសារ ឬម្ចាស់ផ្ទះ ឬបុគ្គលណាមួយដែលបម្រើការងារអោយបុគ្គលដែលត្រូវបានធានារ៉ាប់រង ។

ដោយហេតុថា ចំនួនទឹកប្រាក់ដែលត្រូវបង់ជូនស្ថិតនៅក្នុងផ្នែកនេះសម្រាប់គ្រោះថ្នាក់នីមួយៗ ឬគ្រោះថ្នាក់ផ្សេងៗទៀត ដែលកើតចេញពីហេតុការណ៍តែមួយ មិនត្រូវលើសពីចំនួនទឹកប្រាក់ដែលបានបញ្ជាក់នៅក្នុងតារាងឧបសម្ព័ន្ធសម្រាប់ករណីនីមួយៗ ។

បន្ថែមលើនេះទៅទៀត ក្រុមហ៊ុននឹងធ្វើសំណងចំពោះបុគ្គលដែលត្រូវបានធានារ៉ាប់រងក្នុងករណី :

(ក) ថ្លៃសេវាកម្មផ្នែកច្បាប់ និងការចំណាយផ្សេងៗទៀត ដែលអាចទទួលបានពីបុគ្គលដែលត្រូវបានធានារ៉ាប់រង ដោយសារការប្តឹងទាមទារសំណងរបស់ភាគីដើមបណ្តឹង ដោយហេតុថាថ្លៃ និង ការចំណាយទាំងនោះ ត្រូវបានកើតឡើងមុនពេលដែល (ប្រសិនបើមាន) ក្រុមហ៊ុនធ្វើការបង់ជូន ឬ ផ្តល់ជូន ទោះបីជាបណ្តឹងទាមទារសំណងសរុប ឬចំនួនទឹកប្រាក់សរុបដែលអាចទទួលបានមកវិញពីហេតុការណ៍នីមួយៗដូចដែលបានបញ្ជាក់ជូនខាងលើ

(ខ) ថ្លៃសេវាកម្មផ្នែកច្បាប់ និងការចំណាយផ្សេងៗរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រងដោយមានការឯកភាពជា លាយលក្ខណ៍អក្សរពីក្រុមហ៊ុន ។

ក្រុមហ៊ុនមិនទទួលខុសត្រូវក្នុងករណីដូចខាងក្រោម :

(i) របួស ឬការខូចខាតដែលបណ្តាលមកពី ឬគ្រោះថ្នាក់ជាយថាហេតុចំពោះ :

(ក) អាជីពរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង ឬអាជីវកម្ម ឬ

(ខ) ភាពជាកម្មសិទ្ធិ ភាពជាម្ចាស់ ឬការប្រើប្រាស់ដោយ ឬក្នុងនាមបុគ្គលដែលត្រូវបានធានារ៉ាប់រងចំពោះការប្រើប្រាស់ជណ្តើរយន្ត យានយន្ត កប៉ាល់ ឬមធ្យោបាយធ្វើដំណើរតាមផ្លូវទឹក ឬផ្លូវអាកាសគ្រប់ប្រភេទ

(គ) ការផ្លាស់ប្តូរ ការបន្ថែម ការជួសជុល ឬការកែលំអចំពោះបរិវេណអគារដែលត្រូវបានធានារ៉ាប់រង ។

(ii) ការទទួលខុសត្រូវដែលកើតឡើងដោយសារកិច្ចសន្យាធ្វើសំណងណាមួយ ដែលមានលក្ខណៈចាប់បង្ខំបុគ្គលដែលត្រូវបានធានារ៉ាប់រងអោយទទួលខុសត្រូវនូវអ្វីដែលខ្លួនមិនគួរទទួល ។

ក្នុងករណីបុគ្គលដែលត្រូវបានធានារ៉ាប់រងទទួលមរណភាព ក្រុមហ៊ុននឹងធ្វើសំណងជូនអ្នកតំណាងស្របច្បាប់របស់បុគ្គលដែលត្រូវបានធានារ៉ាប់រងទៅតាមលក្ខខណ្ឌ និងផ្អែកលើដែនកំណត់នៃការផ្តល់ជូននៅក្នុងផ្នែកនេះ ដែលអ្នកតំណាងស្របច្បាប់ទាំងនោះត្រូវប្រតិបត្តិតាមអនុវត្តតាម និងដោយផ្អែកលើខចែងដែលមាននៅក្នុងកិច្ចសន្យាធានារ៉ាប់រងនេះ ។

ផ្នែកនេះមិនអនុវត្តចំពោះផ្នែកណាមួយនៃលំនៅដ្ឋានឯកជន ដែលបានប្រើប្រាស់ជាប់ពាក់ព័ន្ធនឹងអាជីពរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រងក្នុងខណៈពេលដែលផ្នែកណាមួយនៃលំនៅដ្ឋានឯកជននោះកំពុងត្រូវបានគេប្រើប្រាស់ ។

សម្រាប់គោលបំណងនៃផ្នែកនេះពាក្យថា "បុគ្គលដែលត្រូវបានធានារ៉ាប់រង" ត្រូវបានសន្មតរាប់បញ្ចូលទាំងប្តី ឬប្រពន្ធរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង។

**(ខ.) ការធានារ៉ាប់រងលើថ្លៃជួលកន្លែងស្នាក់នៅ-(ត្រូវបានអនុវត្តប្រសិនបើផ្នែកទី២(ខ) ត្រូវបានធានារ៉ាប់រង)**

ក្រុមហ៊ុននឹងធ្វើសំណងជូនបុគ្គលដែលត្រូវបានធានារ៉ាប់រង សម្រាប់ការបាត់បង់ដែលមានបញ្ជាក់ជូនដូចខាងក្រោម ដែលកើតឡើងចំពោះបុគ្គលដែលត្រូវបានធានារ៉ាប់រង និងជាប់ពាក់ព័ន្ធនឹងបរិវេណអគារដូចដែលបានបញ្ជាក់ជូននៅក្នុងតារាងឧបសម្ព័ន្ធ បានទទួលរងការខូចខាតដែលតម្រូវអោយជួលកន្លែងស្នាក់នៅ ប៉ុន្តែសម្រាប់តែរយៈពេលចាំបាច់ក្នុងការធ្វើអោយដូចដើមវិញចំពោះអគារដែលបានខូចខាត និងដោយផ្អែកលើចំនួនទឹកប្រាក់មិនលើសពី ១០% នៃចំនួនទឹកប្រាក់សរុប ឬរហូតដល់ចំនួនកំណត់ជាក់លាក់ដែលមានបញ្ជាក់នៅក្នុងបង្កាន់ដៃ សម្រាប់ចំនួនទឹកប្រាក់សរុបដែលត្រូវធានារ៉ាប់រងលើអគារ និង/ឬទ្រព្យសម្បត្តិ :

(ក) ក្នុងនាមជាម្ចាស់ ប៉ុន្តែមិនមែនជាអ្នកស្នាក់នៅក្នុងបរិវេណអគារ ពោលគឺការបាត់បង់នូវតម្លៃជួលអគារ និង/ឬ

(ខ) ក្នុងនាមជាអ្នកស្នាក់នៅក្នុងបរិវេណអគារ ពោលគឺការចំណាយបន្ថែមចាំបាច់ និងសមហេតុផលសម្រាប់ការជួលសណ្ឋាគារ ផ្ទះសំណាក់ ឬបន្ទប់ផ្ទះជួល ។

ចំនួនទឹកប្រាក់សរុបដែលត្រូវធ្វើសំណងស្ថិតនៅក្រោមផ្នែកនេះនឹងត្រូវបូកបន្ថែមលើចំនួនទឹកប្រាក់សរុបដែលត្រូវធានារ៉ាប់រងលើអគារ និង/ឬទ្រព្យសម្បត្តិ អាស្រ័យលើផ្នែកណាមួយដែលនឹងត្រូវយកមកអនុវត្ត ។

## លក្ខខណ្ឌធានាផ្សេងៗទៀត

**១. លក្ខខណ្ឌកម្រិតលើទំនិញ**

ត្រូវធានាថា ក្នុងអំឡុងពេលដែលកិច្ចសន្យាធានារ៉ាប់រងនេះនៅមានតម្លៃ គ្មានផ្នែកណាមួយនៃបរិវេណអគារដែលមានបញ្ជាក់ ក្នុងកិច្ចសន្យាធានារ៉ាប់រងនេះ ត្រូវបានប្រើប្រាស់ជារោងចក្រ ឬ ដាក់ជាប្រាក់កក់ ឬជាកន្លែងស្តុកទំនិញ ។

**២. លក្ខខណ្ឌបុព្វលាភធានារ៉ាប់រង**

លក្ខខណ្ឌសំខាន់បំផុត និងដាច់ខាតនៃកិច្ចសន្យាធានារ៉ាប់រងនេះ គឺប្រាក់បុព្វលាភដែលដល់ពេលកំណត់ត្រូវបង់ និងទទួលដោយក្រុមហ៊ុនយើងខ្ញុំនៅក្នុងរយៈពេលសាមសិប(៣០)ថ្ងៃ គិតចាប់ពីថ្ងៃចាប់ផ្តើមនៃកិច្ចសន្យាធានារ៉ាប់រង/បង្កាន់ដៃ/ការបន្តវិញ្ញាបនប័ត្រធានារ៉ាប់រងថ្មីនេះ ។

ប្រសិនបើលក្ខខណ្ឌនេះមិនត្រូវបានគោរពទេ កិច្ចសន្យាធានារ៉ាប់រងនេះត្រូវចាត់ទុកជាមោឃៈដោយស្វ័យប្រវត្តិ ហើយក្រុមហ៊ុនយើងខ្ញុំមានសិទ្ធិទទួលបានសមាមាត្រនៃបុព្វលាភសម្រាប់រយៈពេលដែលក្រុមហ៊ុនស្ថិតនៅក្នុងហានិភ័យ ។

នៅពេលដែលបុព្វលាភដែលត្រូវបង់ស្របតាមការធានានេះ ត្រូវបានទទួលដោយភ្នាក់ងារដែលទទួលការអនុញ្ញាតពីក្រុមហ៊ុនយើងខ្ញុំ ការបង់បុព្វលាភនេះត្រូវបានចាត់ទុកថាត្រូវបានទទួលដោយក្រុមហ៊ុនយើងខ្ញុំសម្រាប់គោលបំណងនៃការធានានេះ ហើយក្រុមហ៊ុនយើងខ្ញុំមានបន្ទុកក្នុងការបង្ហាញភស្តុតាងផ្ទុយថា បុព្វលាភនេះត្រូវបានទទួលដោយបុគ្គលមួយរូបរាប់បញ្ចូលទាំងភ្នាក់ងារធានារ៉ាប់រងផងដែរ ដែលពុំត្រូវបានអនុញ្ញាតអោយទទួលបុព្វលាភនេះ ។

រាល់លក្ខខណ្ឌ និងខចែងទាំងអស់ត្រូវផ្អែកលើកិច្ចសន្យាធានារ៉ាប់រងនេះ ។

## ករណីលើកលែងទូទៅ

**កិច្ចសន្យាធានារ៉ាប់រងនេះមិនធ្វើសំណងលើ :**

១. ការបាត់បង់ ឬការខូចខាតដោយថាហេតុណាមួយដែលបង្កឡើងដោយ ឬតាមរយៈ ឬជាប់ពាក់ព័ន្ធដោយផ្ទាល់ ឬប្រយោល នៃហេតុការណ៍ដូចខាងក្រោម :

(ក) សង្គ្រាម ការឈ្លានពាន ទង្វើរបស់សត្រូវបរទេស អរិភាព ឬប្រតិបត្តិការសង្គ្រាម (ទោះបីសង្គ្រាមនោះត្រូវបានប្រកាស ឬមិនប្រកាសក៏ដោយ) សង្គ្រាមស៊ីវិល ។

(ខ) ការបះបោរ កុប្បកម្ម ការក្រោកឈរប្រឆាំងដោយយោធា ឬប្រជាជន ឧទ្ទាមកម្ម បដិវត្តន៍ ការចលាចល ឬការប្រើប្រាស់អំណាចយោធា ឬការដណ្តើមអំណាច ការប្រើប្រាស់ច្បាប់អាជ្ញាសឹក ឬការឡោមព័ទ្ធរដ្ឋ ឬហេតុការណ៍ផ្សេងទៀត ឬមូលហេតុផ្សេងទៀតដែលកំណត់នូវសេចក្តីប្រកាស ឬរក្សានូវការប្រើប្រាស់ច្បាប់អាជ្ញាសឹក ឬការឡោមព័ទ្ធរដ្ឋ។

(គ) សកម្មភាពនៃអំពើភេរវកម្មគ្រប់ប្រភេទ

ចំពោះគោលបំណងនៃកិច្ចសន្យានេះ អំពើភេរវកម្មមានន័យថាជាអំពើជាអាទិ៍ ការប្រើប្រាស់កំលាំង ឬអំពើហិង្សា និង/ឬការគំរាមកំហែងរបស់បុគ្គល ឬក្រុមណាមួយ ទោះបីជាប្រព្រឹត្តតែម្នាក់ឯង ឬក្នុងនាមគេ ឬជាប់ពាក់ព័ន្ធ នឹងអង្គការ ឬរដ្ឋាភិបាលណាមួយក្តី។ អំពើនោះប្រព្រឹត្តក្នុងគោលដៅនយោបាយ សាសនា មនោគមវិជ្ជា ដែលមានចេតនាធ្វើឱ្យមានឥទ្ធិពលលើរដ្ឋាភិបាល និង/ឬធ្វើឱ្យសាធារណជន ឬផ្នែកណាមួយនៃសាធារណជនមានការភ័យខ្លាច។

សម្រាប់ផ្នែកទី ១ ២(ក) ២(ខ) ២(គ) ២(ឃ) និង ៣(ខ) :

ការបាត់បង់ ការខូចខាត ឬមហន្តរាយជាយថាហេតុណាមួយដែលកើតឡើងក្នុងអំឡុងពេលដែលមានអត្ថិភាពនៃលក្ខខណ្ឌមិនប្រក្រតី (ទោះបីជាផ្នែករូបវន្ត ឬមិនមែនក៏ដោយ) ដែលបង្កឡើងដោយ ឬតាមរយៈ ឬជាប់ពាក់ព័ន្ធនឹងហេតុការណ៍ ដែលបានរៀបរាប់ខាងលើទោះបីដោយផ្ទាល់ ឬប្រយោលក្តី នឹងត្រូវបានចាត់ទុកថាជាការបាត់បង់ ការខូចខាត ឬមហន្តរាយ ដែលមិនអាចទទួលបានសំណងតាមរយៈកិច្ចសន្យាធានារ៉ាប់រងនេះឡើយ លើកលែងតែបុគ្គលដែលត្រូវបានធានារ៉ាប់រងអាចផ្តល់ភស្តុតាងថា ការបាត់បង់ ការខូចខាត ឬមហន្តរាយដទៃទៀតបានកើតឡើងដោយឯករាជ្យមិនជាប់ទាក់ទងនឹងអត្ថិភាពនៃលក្ខខណ្ឌមិនប្រក្រតីទាំងនោះ ។

នៅក្នុងសកម្មភាពណាមួយដូចជា ការប្តឹង ឬដំណើរការបណ្តឹងផ្សេងៗទៀតដែលក្រុមហ៊ុនចាត់ទុកថាករណីលើកលែងទូទៅ គឺជាបុរេលក្ខខណ្ឌសម្រាប់រាល់ការបាត់បង់ ការខូចខាត ឬមហន្តរាយដទៃផ្សេងទៀតដែលមិនត្រូវបានធ្វើសំណងស្របតាមកិច្ចសន្យាធានារ៉ាប់រងនេះ នោះបន្ទុកក្នុងការបង្ហាញថាកាបាត់បង់ ការខូចខាត ឬមហន្តរាយទាំងនោះត្រូវបានធ្វើសំណងត្រូវធ្លាក់លើបុគ្គលដែលត្រូវបានធានារ៉ាប់រង ។

២. (i) (ក) ការបាត់បង់ ឬការខូចខាតដែលបង្កឡើងដោយសារការបញ្ឈប់ការងារ ឬដោយសារការរឹបអូសទ្រព្យសម្បត្តិ ការកេណ្ឌ ការជម្លៀស ការបំផ្លាញ ឬមហន្តរាយ ឬការខូចខាតទ្រព្យសម្បត្តិដោយសារតែបទបញ្ជារបស់រដ្ឋាភិបាល អាជ្ញាធររាជធានី ឬអាជ្ញាធរក្នុងស្រុករបស់ប្រទេស ឬតំបន់ដែលទ្រព្យសម្បត្តិទាំងនោះស្ថិតនៅ ឬការខូចខាត ទ្រព្យសម្បត្តិទាំងនោះដោយសារការឡើងមេដោយឯកឯង ការឡើងកំដៅ ឬចំហេះដែលកើតឡើងដោយឯកឯង ឬ ដោយទទួលរងនូវដំណើរការកំដៅ ឬដំណើរការសម្ងួត ។

(ខ) ការបាត់បង់ ការខូចខាត ឬមហន្តរាយផ្សេងៗទៀតដែលកើតឡើងដោយផ្ទាល់ ឬប្រយោលពី ឬបង្កឡើងពី ឬជាប់ពាក់ព័ន្ធនឹង ឬចូលរួមចំណែកបង្កឡើងដោយសព្វាវុធនុយក្លេអ៊ែរ ។

(ii) ការបាត់បង់ ការខូចខាត ឬមហន្តរាយផ្សេងៗទៀតដែលកើតឡើងដោយផ្ទាល់ ឬប្រយោលពី ឬបង្កឡើងពី ឬ ជាប់ពាក់ព័ន្ធនឹង ឬចូលរួមចំណែកបង្កឡើងដោយសារធាតុវិទ្យុសកម្មអ៊ីយ៉ុង ឬការបំពុលដោយសារសកម្មភាព វិទ្យុសកម្មដែលភាយចេញពីសំណល់នុយក្លេអ៊ែរ ឬពីចំហេះឥន្ធនៈនុយក្លេអ៊ែរ។ គោលបំណងតែមួយគត់សម្រាប់ករណីលើកលែងទី ២(ii) គឺ " ចំហេះ " ត្រូវបានរាប់បញ្ចូលទាំងដំណើរការបំបែកសារធាតុនុយក្លេអ៊ែរដោយខ្លួនឯង ។

៣. ការបាត់បង់ ឬការខូចខាតផ្នែកហិរញ្ញវត្ថុគ្រប់ប្រភេទ លើកលែងការផ្តល់ជូនក្នុងផ្នែកទី ៣(ខ) ។

៤. អនុវត្តចំពោះអគារប៉ុណ្ណោះ :

(ក) ការបាត់បង់ ឬការខូចខាត ដែលបង្កឡើងដោយផ្ទាល់ពី ព្យុះសង្ឃរា ព្យុះទីហ្វុង ព្យុះស៊ីក្លូន និងព្យុះភ្លៀង លើអគារណាមួយពេលកំពុងសាងសង់ ការជួសជុល ឬសាងសង់ឡើងវិញ លើកលែងតែផ្នែកខាងក្រៅនៃទ្វារ បង្អួច និងផ្នែកផ្សេងទៀតដែលអាចបើកបានត្រូវបានធ្វើរួចរាល់ និងការពារនូវហានិភ័យទាំងនោះ ឬបំពង់លោហធាតុសំរាប់បញ្ចេញផ្សែង រនាំងបាំងសាច (សំរាប់ដាក់លើទ្វារ ឬបង្អួច) ព្រិលបង្អួច ស្លាកសញ្ញា និងសម្ភារផ្សេងៗទៀត ដែលនៅជាប់នឹងអគារផ្នែកខាងក្រៅរាប់បញ្ចូលទាំងក្លោងទ្វារ និងរបង ។

(ខ) ការខូចខាត ឬការបាត់បង់ដែលបណ្តាលមកពីការធ្លាក់ចុះ ឬបំណាក់ស្រុតដី លើកលែងតែក្នុងករណីបង្កឡើងដោយគ្រោះរញ្ជួយផែនដី ឬបន្ទុះភ្នំភ្លើង។

## លក្ខខណ្ឌទូទៅ

១. កិច្ចសន្យាធានារ៉ាប់រងនេះ និងតារាងឧបសម្ព័ន្ធត្រូវអានជាមួយគ្នាជាកិច្ចសន្យាតែមួយ ហើយចំពោះពាក្យពេចន៍ និងឃ្លាឃ្លោង ដែលមានអត្ថន័យជាក់លាក់ដែលមាននៅក្នុងកិច្ចសន្យាធានារ៉ាប់រង ឬតារាងឧបសម្ព័ន្ធនេះនឹងត្រូវមានអត្ថន័យជាក់លាក់បែបនោះទោះបីជាស្ថិតនៅទីណាក៏ដោយ ។

២. លើកលែងតែត្រូវបានបញ្ជាក់ច្បាស់លាស់ផ្សេងពីនេះ គ្មានការផ្តល់សិទ្ធិណាមួយក្នុងការធ្វើបណ្តឹងប្រឆាំងនឹងក្រុមហ៊ុនអោយទៅបុគ្គលផ្សេងទៀតក្រៅពីបុគ្គលដែលត្រូវបានធានារ៉ាប់រង។ ជាងនេះទៅទៀតក្រុមហ៊ុនមិនជាប់កាតព្វកិច្ចណាមួយ តាមរយៈការផ្ទេរអត្ថប្រយោជន៍ពីបុគ្គលដែលត្រូវបានធានារ៉ាប់រង លើកលែងតែមរណភាពរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង ឬការអនុវត្តច្បាប់ និងលុះត្រាតែមានការបញ្ជាក់របស់ក្រុមហ៊ុនតាមរយៈបដ្ឋិលេខថា កិច្ចសន្យាធានារ៉ាប់រងនេះនៅបន្តមានសុពលភាព ។

៣. វិសាលភាពនៃការទទួលខុសត្រូវរបស់ក្រុមហ៊ុនចំពោះទ្រព្យសម្បត្តិរបស់បុគ្គលណាមួយក្រៅពីបុគ្គលដែលត្រូវបានធានារ៉ាប់រង នឹងមិនផ្តល់សិទ្ធិក្នុងការធ្វើបណ្តឹងទាមទារសំណងចំពោះបុគ្គលទាំងនោះឡើយ ដោយគោលបំណងនៃលក្ខខណ្ឌនេះគឺថាក្នុងគ្រប់ករណីនៃបណ្តឹងទាមទារសំណងទាំងអស់ត្រូវធ្វើឡើងដោយបុគ្គលដែលត្រូវបានធានារ៉ាប់រងក្នុងនាម ឬជំនួសអោយបុគ្គលទាំងនោះ ហើយបង្កាន់ដៃទទួលស្គាល់របស់បុគ្គលដែលត្រូវបានធានារ៉ាប់រងគ្រប់ករណីនីមួយៗត្រូវបានចាត់ទុកថា ការទទួលខុសត្រូវរបស់ក្រុមហ៊ុនត្រូវបានបញ្ចប់ ។

៤. ការបង់ថ្លៃស្នាក់នៅរបស់ភ្ញៀវ អ្នកជួលបន្ទប់ស្នាក់នៅ ឬអ្នកជួលបន្ទប់សំណាក់ មិនត្រូវលើសពីចំនួនបី (៣) នាក់ ដែលត្រូវបានអនុញ្ញាតដោយមិនគិតពីបុរេនិច្ឆ័យនៃការធ្វើសំណងដែលផ្តល់ជូន និងសម្រាប់គោលបំណងនៃផ្នែកទី ៣(ក) នៃកិច្ចសន្យាធានារ៉ាប់រងនេះ ការបង់ថ្លៃស្នាក់នៅរបស់ភ្ញៀវ

អ្នកជួលបន្ទប់ស្នាក់នៅ និងអ្នកជួលបន្ទប់សំណាក់ទាំងនោះ នឹងត្រូវបានចាត់ទុកថាជាសមាជិកគ្រួសាររបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង ។

៥. ចំនួនទឹកប្រាក់សរុបលើការធានារ៉ាប់រងដែលប្រកាសដោយបុគ្គលដែលត្រូវបានធានារ៉ាប់រង ត្រូវតែជាតម្លៃតំណាងអោយអគារ និង/ឬទ្រព្យសម្បត្តិទាំងមូល ហើយការទទួលខុសត្រូវសរុបរបស់ក្រុមហ៊ុនក្នុងករណីដែលមានការបាត់បង់ ឬខូចខាតដែលបង្កឡើងទាំងស្រុងដោយ ឬហានិភ័យណាមួយក្នុងអំឡុងពេលនៃការធានារ៉ាប់រងនីមួយៗ នឹងមិនត្រូវលើសពីចំនួនទឹកប្រាក់ សម្រាប់ផ្នែកនីមួយៗ ឬចំនួនទឹកប្រាក់សរុបដែលត្រូវបានធានារ៉ាប់រងដូចដែលបានបញ្ជាក់នៅក្នុងតារាងឧបសម្ព័ន្ធ ឬចំនួនទឹកប្រាក់បូកសរុប ឬទឹកប្រាក់សរុបដែលអាចត្រូវជំនួសដោយអនុស្សរណៈ ឬក៏ភ្ជាប់ដោយការចុះហត្ថលេខាដោយ ឬក្នុងនាមក្រុមហ៊ុន ។

៦. ប្រសិនបើទ្រព្យសម្បត្តិទាំងអស់ដែលត្រូវបានធានារ៉ាប់រង ត្រូវបានបាត់បង់ ឬខូចខាតលើសពីទំហំទឹកប្រាក់ដែលត្រូវបានធានារ៉ាប់រងក្នុងខណៈពេលដែលមានការបាត់បង់ ឬការខូចខាតកើតឡើង នោះបុគ្គលដែលត្រូវបានធានារ៉ាប់រង ត្រូវបានចាត់ទុកថាជាអ្នកធានារ៉ាប់រងដោយខ្លួនឯងផ្ទាល់សម្រាប់ភាពខុសគ្នានោះ និងត្រូវទទួលខុសត្រូវសម្រាប់អត្រាសមាមាត្រនៃការបាត់បង់។ ទ្រព្យសម្បត្តិនីមួយៗ ប្រសិនបើមានលើសពីមួយដូចដែលបានបញ្ជាក់ជូននៅក្នុងតារាងឧបសម្ព័ន្ធនឹងត្រូវអនុវត្តដាច់ដោយឡែកពីគ្នាដោយផ្អែកលើលក្ខខណ្ឌនេះ ។

៧. ប្រសិនបើនៅពេលបាត់បង់ ខូចខាត ឬការទទួលខុសត្រូវ ត្រូវបានធ្វើសំណងដោយកិច្ចសន្យាធានារ៉ាប់រងនេះ មានការធានារ៉ាប់រងផ្សេងទៀតចំពោះការបាត់បង់ ការខូចខាត ឬការទទួលខុសត្រូវនោះ នោះក្រុមហ៊ុននឹងមិនទទួលខុសត្រូវ ច្រើនជាងសមាមាត្រដែលខ្លួនត្រូវទទួលខុសត្រូវឡើយ ។

៨. បុគ្គលដែលត្រូវបានធានារ៉ាប់រង ត្រូវផ្តល់ព័ត៌មានជាលាយលក្ខណ៍អក្សរដល់ក្រុមហ៊ុនអំពីការធានារ៉ាប់រង ឬការធានារ៉ាប់រងផ្សេងទៀតដែលមានសុពលភាព ឬដែលអាចមានសុពលភាពលើទ្រព្យសម្បត្តិដែលត្រូវបានធានារ៉ាប់រងណាមួយ ហើយលុះត្រាតែមានការជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ក្រុមហ៊ុន និងមានការបញ្ជាក់នូវការធានារ៉ាប់រងនោះ ឬការធានារ៉ាប់រង ផ្សេងទៀតដែលមានបញ្ជាក់នៅក្នុង ឬបដ្ឋិលេខដែលមាននៅក្នុងកិច្ចសន្យាធានារ៉ាប់រងនេះដោយ ឬក្នុងនាមក្រុមហ៊ុន មុនពេលកើតមាននូវការបាត់បង់ ឬការខូចខាតណាមួយ នោះអត្ថប្រយោជន៍ទាំងអស់ដែលស្ថិតនៅក្នុងកិច្ចសន្យាធានារ៉ាប់រងនេះ ពោលគឺទ្រព្យសម្បត្តិដែលត្រូវបានធានារ៉ាប់រងទាំងអស់ត្រូវបានចាត់ទុកជាមោឃៈ ។

៩. (ក) បុគ្គលដែលត្រូវបានធានារ៉ាប់រង ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាបន្ទាន់មកកាន់ក្រុមហ៊ុននៅពេលដែលមានការបាត់បង់ ឬខូចខាតចំពោះទ្រព្យសម្បត្តិដែលត្រូវបានធានារ៉ាប់រង ហើយក្រោមការចំណាយផ្ទាល់ខ្លួនក្នុងរយៈពេល ៣០ ថ្ងៃបន្ទាប់ពីមានការបាត់បង់ ឬការខូចខាតទាំងនោះ ត្រូវផ្តល់ដល់ក្រុមហ៊ុននូវបណ្តឹងទាមទារសំណងជាលាយលក្ខណ៍អក្សរ ដោយមានការបញ្ជាក់លម្អិតអំពីផ្នែកនីមួយៗ និងភស្តុតាងផ្សេងៗទៀតដែលអាច ត្រូវបានតម្រូវដោយសមហេតុផល។ ក្នុងករណីដែលមានការបាត់បង់ ឬខូចខាតដោយអំពើចោរកម្ម ឬការប៉ុនប៉ងណាមួយ បុគ្គលដែលត្រូវបានធានារ៉ាប់រងត្រូវផ្តល់ព័ត៌មានជាបន្ទាន់ដល់មន្ត្រីនគរបាល ។

(ខ) ប្រសិនបើក្រុមហ៊ុនជ្រើសរើសយកការសាងសង់អគារណាមួយ អោយមានសភាពដូចដើមវិញ បុគ្គលដែលត្រូវបានធានារ៉ាប់រងត្រូវផ្តល់ដល់ក្រុមហ៊ុននូវប្លង់ បរិមាណ និង តារាងលម្អិតរបស់អគារដែលអាចត្រូវបានតម្រូវដោយក្រុមហ៊ុន។

(គ) ក្នុងករណីទទួលបាននូវការជូនដំណឹងអំពីគ្រោះថ្នាក់ណាមួយ ឬមានបណ្តឹងទាមទារសំណងកើតឡើងនៅក្នុងផ្នែកទី ៣

(ក) បុគ្គលដែលត្រូវបានធានារ៉ាប់រង ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាបន្ទាន់មកក្រុមហ៊ុន និងផ្តល់ព័ត៌មានលម្អិតផ្សេងៗ ព្រមទាំងផ្តល់នូវលិខិតបង្គាប់ ដីកាកោះហៅអោយចូលខ្លួន លិខិតគតិយុត្តិផ្សេងៗទៀតដែលជំទាស់ ឬប្រឆាំងនឹងបុគ្គលដែលត្រូវបានធានារ៉ាប់រង និងផ្តល់នូវជំនួយ និងព័ត៌មានចាំបាច់ទាំងឡាយដើម្បីអោយក្រុមហ៊ុន អាចដោះស្រាយ ឬតទល់ចំពោះបណ្តឹងទាមទារសំណងណាមួយ ឬបណ្តឹងផ្លូវច្បាប់ផ្សេងៗទៀត ។

(ឃ) បុគ្គលដែលត្រូវបានធានារ៉ាប់រងមិនត្រូវធ្វើការចំណាយណាមួយក្នុងការធ្វើអោយដូចដើម ឬប្រសើរឡើងនូវការខូចខាតណាមួយដោយមិនមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីក្រុមហ៊ុន និងមិនត្រូវចរចា បង់ជូន ដោះស្រាយ ទទួលស្គាល់ ឬបដិសេធនូវបណ្តឹងទាមទារសំណងណាមួយដោយមិនមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីក្រុមហ៊ុននោះឡើយ ។

១០. ក្រុមហ៊ុនមានសិទ្ធិ :

(ក) ក្នុងករណីមានការបាត់បង់ ឬការខូចខាតចំពោះទ្រព្យសម្បត្តិដែលត្រូវបានធានារ៉ាប់រង ក្រុមហ៊ុនមានសិទ្ធិចូលក្នុងអគារដែលមានការខូចខាត ឬបាត់បង់នោះ និងមានសិទ្ធិកាន់កាប់នូវទ្រព្យសម្បត្តិដែលត្រូវបានធានារ៉ាប់រង និងដោះស្រាយនូវទ្រព្យសម្បត្តិដែលមានការខូចខាតដើម្បីលក់ស្រង់ដើមវិញក្នុងលក្ខណៈសមស្រប ហើយកិច្ចសន្យាធានារ៉ាប់រងនេះ ឬច្បាប់ថតចម្លងដែលមានការបញ្ជាក់ពីក្រុមហ៊ុន នឹងក្លាយជាភស្តុតាងតែមួយគត់សម្រាប់ការអនុញ្ញាត ឬផ្តល់សិទ្ធិសម្រាប់គោលបំណងទាំងនោះ។ គ្មានទ្រព្យសម្បត្តិណាមួយអាចត្រូវបានលះបង់ជូន ក្រុមហ៊ុននោះឡើយ។

(ខ) ក្រុមហ៊ុនមានសិទ្ធិក្នុងនាម និងជួសអោយបុគ្គលដែលត្រូវបានធានារ៉ាប់រងក្នុងការរៀបចំ គ្រប់គ្រង និងដោះស្រាយរាល់បណ្តឹងណាមួយ និងធ្វើការប្តឹងក្រោមចំណាយផ្ទាល់ខ្លួន និងដើម្បីអត្ថប្រយោជន៍របស់ក្រុមហ៊ុនដើម្បីទទួលបានសំណងមកវិញ ប៉ុន្តែក្នុងនាមបុគ្គលដែលត្រូវបានធានារ៉ាប់រង ឬទទួលបានសំណងពីភាគីតតិយជនណាមួយក្នុងករណី ដែលការបាត់បង់ត្រូវបានធានារ៉ាប់រងដោយកិច្ចសន្យានេះ ។

១១. ប្រសិនបើការទាមទារសំណងណាមួយដែលស្ថិតក្រោមកិច្ចសន្យាធានារ៉ាប់រងនេះ ត្រូវបានធ្វើឡើងដោយក្លែងបន្លំ ឬប្រើប្រាស់មធ្យោបាយក្លែងបន្លំណាមួយ

ឬឧបាយកលផ្សេងៗ ត្រូវបានប្រើប្រាស់ដោយបុគ្គលដែលត្រូវបានធានារ៉ាប់រង ឬដោយនរណាម្នាក់ដែលតំណាងអោយបុគ្គលដែលត្រូវបានធានារ៉ាប់រង ដើម្បីទទួលបាននូវអត្ថប្រយោជន៍ស្របតាមកិច្ចសន្យាធានារ៉ាប់រងនេះ នោះរាល់អត្ថប្រយោជន៍ទាំងអស់ត្រូវចាត់ទុកជាអសារបង់ ។

១២. ការធានារ៉ាប់រងនេះអាចត្រូវបានបញ្ចប់នៅពេលណាមួយតាមសំណើរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង ដោយជូនដំណឹងជាលាយលក្ខណ៍អក្សរក្នុងរយៈពេល ១០ថ្ងៃ ក្នុងករណីនេះក្រុមហ៊ុននឹងបង់ជូនបុគ្គលដែលត្រូវបានធានារ៉ាប់រងនូវបុព្វលាភធានារ៉ាប់រងចំនួន ៩០% សំរាប់រយៈពេលដែលនៅមានសុពលភាពគិតចាប់ពីថ្ងៃមោឃភាពនៃកិច្ចសន្យាធានារ៉ាប់រងនេះ ដោយក្នុងលក្ខខណ្ឌថា ពុំមានបណ្តឹងទាមទារសំណងណាមួយកើតឡើងក្នុងអំឡុងពេលនៃការធានារ៉ាប់រងនេះទេ។ កិច្ចសន្យាធានារ៉ាប់រងនេះក៏អាចត្រូវបានបញ្ចប់ផងដែរ តាមជម្រើសរបស់ក្រុមហ៊ុន ដោយធ្វើការជូនដំណឹងជាលាយលក្ខណ៍អក្សរក្នុងរយៈពេល ១០ថ្ងៃ ជាមុនតាមរយៈលិខិតអនុសិដ្ឋទៅកាន់អាសយដ្ឋានដែលគេស្គាល់ចុងក្រោយរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង ក្នុងករណីនេះក្រុមហ៊ុននឹងបង់ជូនបុគ្គលដែលត្រូវបានធានារ៉ាប់រងនូវអត្រាបុព្វលាភធានារ៉ាប់រង តាមអត្រាសមាមាត្រសម្រាប់រយៈពេលដែលនៅមានសុពលភាពគិតចាប់ពីថ្ងៃមោឃភាពនៃកិច្ចសន្យាធានារ៉ាប់រងនេះ។

១៣. ក្នុងករណីមានវិវាទកើតឡើងទាក់ទងទៅនឹងចំនួនទឹកប្រាក់នៃការបាត់បង់ ឬការខូចខាត វិវាទនោះដោយឯករាជ្យពីបញ្ហាផ្សេងទៀតទាំងអស់ ត្រូវបញ្ជូនទៅធ្វើការដោះស្រាយដោយមជ្ឈត្តករម្នាក់ដែលត្រូវតែងតាំងជាលាយលក្ខណ៍អក្សរដោយគូភាគីនៃវិវាទ ឬប្រសិនបើពួកគេមិនឯកភាពអោយមានមជ្ឈត្តករម្នាក់នឹងត្រូវបញ្ជូនទៅធ្វើការដោះស្រាយដោយបុគ្គលគ្មានទំនាស់ផលប្រយោជន៍ពីរនាក់ដែលត្រូវធ្វើជាមជ្ឈត្តករ ដែលមជ្ឈត្តករម្នាក់ត្រូវតែងតាំងឡើងជាលាយលក្ខណ៍អក្សរ ដោយភាគីនីមួយៗក្នុងរយៈពេលពីរ (២)ខែ បន្ទាប់ពីត្រូវបានតម្រូវអោយធ្វើដូច្នោះជាលាយលក្ខណ៍អក្សរដោយភាគីម្ខាងទៀត។ ក្នុងករណីភាគីណាមួយបដិសេធ ឬខកខានមិនបានតែងតាំងមជ្ឈត្តករម្នាក់ក្នុងរយៈពេលពីរ (២)ខែ ក្រោយពេលទទួលបានការជូនដំណឹងជាលាយលក្ខណ៍អក្សរ ដែលស្នើអោយធ្វើការតែងតាំងភាគីម្ខាងទៀតមានសេរីភាពក្នុងការតែងតាំងមជ្ឈត្តករតែមួយ។ ហើយក្នុងករណីមានការមិនព្រមព្រៀងគ្នារវាងមជ្ឈត្តករទាំងពីរ វិវាទត្រូវបញ្ជូនទៅធ្វើការដោះស្រាយដោយអ្នកវិនិច្ឆ័យដែលត្រូវបានតែងតាំងជាលាយលក្ខណ៍អក្សរដោយមជ្ឈត្តករទាំងពីរ មុនពេលចាប់ផ្តើមបញ្ជូន និងដែលត្រូវអង្គុយជាមួយមជ្ឈត្តករ និងធ្វើជាអធិបតីនៅក្នុងកិច្ចប្រជុំ។ មរណភាពរបស់ភាគីណាមួយមិនត្រូវដកហូត ឬមានឥទ្ធិពលលើអំណាច ឬសិទ្ធិអំណាចរបស់មជ្ឈត្តករ ឬអ្នកវិនិច្ឆ័យឡើយ។ ហើយក្នុងករណីមជ្ឈត្តករម្នាក់ ឬអ្នកវិនិច្ឆ័យទទួលមរណភាព មជ្ឈត្តករម្នាក់ទៀត ឬអ្នកវិនិច្ឆ័យនឹងត្រូវតែងតាំងអោយជំនួសមជ្ឈត្តករ ឬអ្នកវិនិច្ឆ័យដែលទទួលមរណភាពដោយគូភាគី ឬមជ្ឈត្តករ (តាមករណីនីមួយៗ) ដែលបានតែងតាំងមជ្ឈត្តករ ឬអ្នកវិនិច្ឆ័យដែលទទួលមរណភាព។ ថ្លៃចំណាយលើការបញ្ជូនរឿងក្តី និងវិនិច្ឆ័យ គឺជាឆន្ទានុសិទ្ធិរបស់មជ្ឈត្តករ ឬអ្នកវិនិច្ឆ័យដែលចេញមជ្ឈត្តវិនិច្ឆ័យជាអ្នកកំណត់។ ភាគីទាំងពីរបានកំណត់ និងប្រកាសយ៉ាងច្បាស់លាស់ថា វាគឺជាលក្ខខណ្ឌជាមុនចំពោះសិទ្ធិចាត់វិធានការ ឬប្តឹងចំពោះកិច្ចសន្យាធានារ៉ាប់រងនេះ ដែលមជ្ឈត្តវិនិច្ឆ័យដោយមជ្ឈត្តករ ឬ អ្នកវិនិច្ឆ័យនៃទំហំទឹកប្រាក់នៃការបាត់បង់ ឬខូចខាតប្រសិនបើមានវិវាទកើតឡើងត្រូវទទួលបានជាដំបូង ។

១៤. បុគ្គលដែលត្រូវបានធានារ៉ាប់រង ត្រូវប្រើប្រាស់គ្រប់មធ្យោបាយសមស្របទាំងអស់និងថែរក្សាបរិវេណអគារអោយស្ថិតនៅក្នុងសភាពល្អប្រសើរជានិច្ច ហើយក្នុងនាមបុគ្គលដែលត្រូវបានធានារ៉ាប់រងដែលជាម្ចាស់នៃលំនៅដ្ឋានឯកជន ប្រសិនបើមានភាពខ្វះចន្លោះ (អនិបុណភាព) ណាមួយត្រូវបានរកឃើញ ត្រូវធ្វើការជួសជុលកែលំអអោយបានឆាប់រហ័ស ហើយក្នុងហេតុផលនេះដែរ ការការពារបន្ថែមត្រូវបានអនុវត្តដើម្បីបង្ការនូវរបួស ការបាត់បង់ ឬការខូចខាតដែលស្ថានភាពទាំងនោះអាចត្រូវបានតម្រូវ ហើយក្រុមហ៊ុនមិនមានកាតព្វកិច្ចទទួលខុសត្រូវចំពោះរបួស ការបាត់បង់ ឬការខូចខាតដែលបណ្តាលមកពីភាពខ្វះចន្លោះ ដោយបុគ្គលដែលត្រូវបានធានារ៉ាប់រងបានបរាជ័យក្នុងការបង្ការ បន្ទាប់ពីទទួលបានការជូនដំណឹងអំពីភាពខ្វះចន្លោះទាំងនោះ ទោះបីតាមរយៈក្រុមហ៊ុន ឬបុគ្គល ឬអាជ្ញាធរសាធារណៈណាមួយ ។

១៥. ក្នុងករណីមានការបាត់បង់ ការធានារ៉ាប់រងត្រូវរក្សាជាធរមានសម្រាប់ចំនួនទឹកប្រាក់សរុបដែលត្រូវបានធានារ៉ាប់រង ហើយបុគ្គលត្រូវបានធានារ៉ាប់រងត្រូវទទួលខុសត្រូវបង់បុព្វលាភធានារ៉ាប់រងបន្ថែមតាមអត្រាដែលមានចែងនៅក្នុងកិច្ចសន្យាធានារ៉ាប់រង ដែលគណនាចេញពីទឹកប្រាក់នៃការបាត់បង់តាមអត្រាសមាមាត្រចាប់ពីកាលបរិច្ឆេទនៃការបាត់បង់រហូតដល់ពេលផុតកំណត់រយៈពេលធានារ៉ាប់រងបច្ចុប្បន្ន ។

១៦. ក្នុងករណីបាត់បង់ទ្រព្យសម្បត្តិដែលត្រូវបានធានារ៉ាប់រង (ក្រៅពីទំនិញក្នុងស្តុក និងសម្ភារសាងសង់) ក្រុមហ៊ុនត្រូវសង តម្លៃដែលត្រូវបានធានារ៉ាប់រង ឬតម្លៃទីផ្សារនៃទ្រព្យសម្បត្តិដែលត្រូវបានធានារ៉ាប់រង ដោយជ្រើសរើសយកទឹកប្រាក់ណាមួយដែលទាបជាងគេ ហើយត្រូវធ្វើការកាត់ចំនួនទឹកប្រាក់ដែលត្រូវចូលរួមចំណែកធ្វើសំណង និងចំនួនទឹកប្រាក់ដែលបុគ្គលត្រូវបានធានារ៉ាប់រងចាំបាច់ត្រូវទទួលបន្ទុកស្របតាមកិច្ចសន្យាធានារ៉ាប់រងនេះ ។

សម្រាប់គោលបំណងនៃលក្ខខណ្ឌនេះ ពាក្យថាតម្លៃទីផ្សារ សំដៅដល់តម្លៃរបស់ទ្រព្យសម្បត្តិដែលត្រូវបានធានារ៉ាប់រងនៅពេលខូចខាត ឬបាត់បង់ ដកនឹងវិភាជន៍ សមស្របសម្រាប់សំណឹករេចរឹលធម្មតា និង/ឬការកាត់រំលស់ ។

សម្រាប់គោលបំណងនៃលក្ខខណ្ឌនេះ តម្លៃទីផ្សាររបស់ទ្រព្យសម្បត្តិដែលត្រូវបានធានារ៉ាប់រង ត្រូវកំណត់ដោយការវាយតម្លៃដែលក្រុមហ៊ុនទទួលបានពីអ្នកផលិត ភ្នាក់ងារលក់ផ្តាច់មុខមានការអនុញ្ញាត ឬភ្នាក់ងារអន្តរការីមានការអនុញ្ញាតអ្នកចែកចាយមានការអនុញ្ញាត ឬអ្នកម៉ៅការសាងសង់លើថ្លៃចំណាយក្នុងការផ្លាស់ចេញថ្មី ឬជួសជុលអោយដូចដើម ដោយត្រូវអនុវត្តការកាត់រំលស់សមស្របនៃទ្រព្យសម្បត្តិរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រងដែលខូចខាត ឬបាត់បង់អោយមានសភាពដូចនៅមុនពេលមានការកើតឡើងនូវការខូចខាត ឬការបាត់បង់នោះ ។

នៅពេលខូចខាត ឬបាត់បង់ ប្រសិនបើគ្មានអ្នកផលិត ភ្នាក់ងារលក់ផ្តាច់មុខមានការអនុញ្ញាត ឬភ្នាក់ងារអន្តរការីមានការអនុញ្ញាត អ្នកចែកចាយមានការអនុញ្ញាត ឬអ្នកម៉ៅការសាងសង់សម្រាប់ទ្រព្យសម្បត្តិដែលត្រូវបានធានារ៉ាប់រងទេ ការវាយតម្លៃត្រូវធ្វើឡើងដោយក្រុមហ៊ុនត្រួតពិនិត្យហានិភ័យធានារ៉ាប់រង ឬអ្នកវាយតម្លៃចុះបញ្ជីត្រឹមត្រូវដែលត្រូវតែងតាំងជាមួយគ្នាដោយភាគីទាំងពីរ ។ ការវាយតម្លៃលើទ្រព្យសម្បត្តិដែលត្រូវបានធានារ៉ាប់រងដោយអ្នកផលិតភ្នាក់ងារ លក់ផ្តាច់មុខមានការអនុញ្ញាត ឬភ្នាក់ងារអន្តរការីមានការអនុញ្ញាត អ្នកចែកចាយមានការអនុញ្ញាត អ្នកម៉ៅការសំណង់ ក្រុមហ៊ុនត្រួតពិនិត្យហានិភ័យធានារ៉ាប់រង ឬអ្នកវាយតម្លៃចុះបញ្ជីត្រឹមត្រូវ គឺជាភស្តុតាងសន្និដ្ឋានទាក់ទងនឹងតម្លៃទីផ្សារនៃទ្រព្យសម្បត្តិដែលត្រូវបានធានារ៉ាប់រងនៅក្នុងការប្តឹងផ្លូវច្បាប់ប្រឆាំងនឹងក្រុមហ៊ុន ។

## ១៧. លក្ខខណ្ឌនៃការទទួលស្គាល់នូវកាលបរិច្ឆេទ (ជាមួយនឹងលក្ខខណ្ឌរក្សាទុក)

វាគឺជាការកត់សម្គាល់ និងព្រមព្រៀងថា កិច្ចសន្យាធានារ៉ាប់រងនេះត្រូវបានកែប្រែដូចខាងក្រោម :

(ក) ក្រុមហ៊ុនមិនធ្វើសំណងសម្រាប់ការបាត់បង់ ឬការខូចខាតណាមួយរួមមាន ការបាត់បង់នូវតម្លៃប្រើប្រាស់ដោយមាន ឬមិនមានការខូចខាតផ្នែករូបវន្ត របួស (រួមទាំងរបួសលើរាងកាយ) ការចំណាយដែលកើតឡើងដោយ ឬកើតឡើងពីដំណើរការខុសប្រក្រតី ឬអសមត្ថភាពផ្នែកប្រព័ន្ធកុំព្យូទ័រណាមួយ ឧបករណ៍ផ្ទុកទិន្នន័យ ប្រព័ន្ធបញ្ជូនព័ត៌មាន (microchip) ប្រព័ន្ធត្រួតពិនិត្យប្រតិបត្តិការរបស់កុំព្យូទ័រ (operating system) ប្រព័ន្ធ Microprocessors (ផែបររបស់កុំព្យូទ័រ) គ្រឿងអេឡិចត្រូនិចតូចៗ (integrated circuit) ឬឧបករណ៍ស្រដៀងគ្នានេះ ឬប្រព័ន្ធសូហ្វែររបស់កុំព្យូទ័រណាមួយ ទោះបីជាទ្រព្យសម្បត្តិរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង ឬមិនមែនក៏ដោយ ហើយទោះបីជាកើតឡើងមុនពេល ក្នុងអំឡុងពេល ឬបន្ទាប់ពីឆ្នាំ ២០០០ ដែលបណ្តាលមកពីដំណើរការមិនប្រក្រតី ឬអសមត្ថភាពនៃឧបករណ៍ និង/ឬប្រព័ន្ធសូហ្វែរទាំងនោះដូចបានរៀបរាប់ខាងលើ ដែលលទ្ធផលនោះបណ្តាលអោយ :

១. មានការកែតម្រូវនូវកាលបរិច្ឆេទណាមួយអោយដូចកាលបរិច្ឆេទក្នុងប្រតិទិន

២. ការចាប់យកការរក្សាទុក ឬបង្ខាំងទុក និង/ឬការរៀបចំដោយត្រឹមត្រូវ ការបកស្រាយ ឬដំណើរការកាលបរិច្ឆេទណាមួយ ឬព័ត៌មាន ឬពាក្យបញ្ជា ឬការណែនាំដែលជាលទ្ធផលនៃការកែតម្រូវកាលបរិច្ឆេទណាមួយ ក្រៅអំពីកាលបរិច្ឆេទត្រឹមត្រូវក្នុងប្រតិទិន និង /ឬ

៣. ការចាប់យកការរក្សាទុក ឬបង្ខាំងទុក ឬដំណើរការទិន្នន័យត្រឹមត្រូវណាមួយដែលជាលទ្ធផលបានមកពី ប្រព័ន្ធប្រតិបត្តិការនៃពាក្យបញ្ជាដែលត្រូវបានគេបញ្ចូលកម្មវិធីទៅក្នុងសូហ្វែរកុំព្យូទ័រណាមួយ ហើយត្រូវបានគេប្រើពាក្យបញ្ជានោះដែលធ្វើអោយបាត់បង់ទិន្នន័យ ឬអសមត្ថភាពក្នុងការចាប់យក ការរក្សាទុក ការបង្ខាំងទុក ឬដំណើរការកែប្រែទិន្នន័យទាំងនោះក្នុង ឬបន្ទាប់ពីកាលបរិច្ឆេទណាមួយ ។

(ខ) ជាងនេះទៅទៀតវាជាការយល់ព្រមថា ក្រុមហ៊ុនមិនធ្វើសំណងណាមួយសម្រាប់ការជួសជុល ឬការកែប្រែផ្នែកប្រព័ន្ធប្រតិបត្តិការទិន្នន័យអេឡិចត្រូនិចណាមួយ ឬផ្នែកណាមួយនៃឧបករណ៍ និង/ឬ សូហ្វែរ ដូចដែលបានរៀបរាប់ក្នុងចំណុច (ក) ខាងលើ ។

(គ) ជាងនេះទៀតវាជាការយល់ព្រមថា ក្រុមហ៊ុនមិនធ្វើសំណងសម្រាប់ការបាត់បង់ ឬការខូចខាតណាមួយ រួមទាំងការបាត់បង់នូវតម្លៃប្រើប្រាស់ដោយមាន ឬមិនមានការខូចខាតផ្នែករូបវន្ត របួស (រួមទាំងរបួសលើរាងកាយ) ការចំណាយផ្សេងៗ ឬការខាតបង់ផ្នែកហិរញ្ញវត្ថុណាមួយដែលកើតឡើងដោយផ្ទាល់ ឬមិនផ្ទាល់ពីការផ្តល់ដំបូន្មានណាមួយ ការពិគ្រោះយោបល់ ការរៀបចំគម្រោង ការវាយតម្លៃ ការស៊ើបអង្កេត ការតម្លើង ការថែទាំ ការជួសជុល ឬការគ្រប់គ្រងដែលបានធ្វើឡើងដោយ ឬក្នុងនាមបុគ្គលដែលត្រូវបានធានារ៉ាប់រង ឬដោយ ឬសម្រាប់បុគ្គលផ្សេងទៀតដើម្បីកំណត់ កែតម្រូវ ឬសាកល្បងដំណើរខុសប្រក្រតីជាក់ស្តែង ឬដែលអាចកើតមានការមិនដំណើរការ ឬភាពមិនត្រឹមត្រូវដែលបានបញ្ជាក់ជូននៅក្នុងចំនុច (ក) ខាងលើ ។

(ឃ) ជាងនេះទៅទៀតវាជាការយល់ព្រមថា ក្រុមហ៊ុនមិនធ្វើសំណងសម្រាប់ការខាតបង់ផ្នែកហិរញ្ញវត្ថុណាមួយ ដែលបណ្តាលមកពីការបន្តប្រើប្រាស់នូវប្រព័ន្ធកុំព្យូទ័រ និងឧបករណ៍ផ្សេងទៀតដែលអសមត្ថភាព ដូចដែលបានរៀបរាប់នៅ ក្នុងចំនុច(ក)ខាងលើ ដើម្បីកែតម្រូវនូវកាលបរិច្ឆេទណាមួយអោយដូចកាលបរិច្ឆេទពិតប្រាកដក្នុងប្រតិទិនបន្ទាប់ពី ទ្រព្យសម្បត្តិដែលបានបាត់បង់ ឬខូចខាតត្រូវបានផ្លាស់ប្តូរ ឬជួសជុល ។

ការបាត់បង់ ឬការខូចខាត របួស (រួមទាំងរបួសលើរាងកាយ) ការចំណាយ ឬការខាតបង់ផ្នែកហិរញ្ញវត្ថុទាំងនោះ ដែលមាននៅក្នុងចំនុច (ក) (ខ) (គ) ឬ(ឃ) ខាងលើត្រូវបានបដិសេធក្នុងការទាមទារសំណង ដោយមិនគិតពីមូលហេតុណាមួយផ្សេងទៀតដែលចូលរួមចំណែកជាមួយគ្នា ឬមូលហេតុដទៃទៀតដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា ។

បដិលេខនេះរាប់បញ្ចូលផងដែរនូវការបាត់បង់ ឬការខូចខាតដែលកើតឡើងជាបន្តបន្ទាប់ ឬការខាតបង់ផ្នែកហិរញ្ញវត្ថុ ដែលបណ្តាលមកពីហានិភ័យដែលត្រូវបានធានារ៉ាប់រងដូចដែលបានបញ្ជាក់ជូនក្នុងកិច្ចសន្យាធានារ៉ាប់រងនេះ ។

រាល់លក្ខខណ្ឌ និង ខ ចែងទាំងអស់ត្រូវផ្អែកលើកិច្ចសន្យាធានារ៉ាប់រងនេះ ។

## ១៨. ខ ចែងស្តីពីប្រព័ន្ធព័ត៌មានវិទ្យា

ការខូចខាតទ្រព្យសម្បត្តិដែលត្រូវបានធានាស្របតាមការធានារ៉ាប់រងនេះ សំដៅដល់ការខូចខាតផ្នែករូបវន្តនៃលក្ខណៈសំខាន់ របស់ទ្រព្យសម្បត្តិ ។

ការខូចខាតផ្នែករូបវន្តនៃលក្ខណៈសំខាន់របស់ទ្រព្យសម្បត្តិមិនរាប់បញ្ចូលការខូចខាតទិន្នន័យ ឬកម្មវិធីកុំព្យូទ័រឡើយ ជាពិសេសការផ្លាស់ប្តូរមិនល្អនៅក្នុងទិន្នន័យ ឬកម្មវិធីកុំព្យូទ័រដែលបង្កឡើងដោយការលុប ការប្រែប្រួល ឬការខូចទ្រង់ទ្រាយនៃរចនាសម្ព័ន្ធដើម ។

ដោយហេតុនេះ ចំណុចខាងក្រោមនេះត្រូវបានលើកលែងពីការធានារ៉ាប់រងនេះ :

(ក) ការបាត់បង់ ឬការខូចខាតទិន្នន័យ ឬកម្មវិធីកុំព្យូទ័រ ជាពិសេសការផ្លាស់ប្តូរមិនល្អនៅក្នុងទិន្នន័យ ឬកម្មវិធីកុំព្យូទ័រដែលបណ្តាលមកពីការលុបចោលការប្រែប្រួល ឬការខូចទ្រង់ទ្រាយនៃរចនាសម្ព័ន្ធដើម និងការបាត់បង់ដោយសារការផ្អាកអាជីវកម្មដែលបង្កឡើងដោយសារការបាត់បង់ ឬការខូចខាតនោះ។ ទោះបីជា មានការលើកលែងនេះក៏ដោយ ការបាត់បង់ ឬការខូចខាតទិន្នន័យ ឬកម្មវិធីកុំព្យូទ័រដែលជាលទ្ធផលដោយផ្ទាល់នៃការខូចខាតផ្នែករូបវន្តដែលមានការធានារ៉ាប់រងដល់លក្ខណៈសំខាន់នៃទ្រព្យសម្បត្តិត្រូវបានគ្របដណ្តប់ ។

(ខ) ការបាត់បង់ ឬ ការខូចខាតដែលបណ្តាលមកពីភាពអន់ថយផ្នែកមុខងារ ភាពអាចរកបានកម្រិតនៃការប្រើប្រាស់ ឬភាពអាចបើកមើលបាននៃទិន្នន័យ ឬកម្មវិធីកុំព្យូទ័រ និងការខាតបង់ដោយសារការផ្អាកអាជីវកម្ម ដែលបង្កឡើងដោយសារការបាត់បង់ ឬការខូចខាតនោះ ។

## ១៩. ខ ចែងស្តីអំពីករណីលើកលែងលើ សារធាតុវិទ្យុសកម្ម/ហានិភ័យថាមពលនុយក្លេអ៊ែរ

កិច្ចសន្យាធានារ៉ាប់រងនេះមិនធ្វើសំណងលើការបាត់បង់ ការខូចខាត ថ្លៃចំណាយ ឬការចំណាយផ្សេងៗ ទោះបីដោយផ្ទាល់ ឬប្រយោលក្តី ដែលបណ្តាលមកពី ឬជាលទ្ធផលបណ្តាលមកពី ឬជាប់ពាក់ពន្ធ័នឹងករណីដូចខាងក្រោម ដោយមិនគិតពីមូលហេតុផ្សេងទៀត ឬហេតុការណ៍ដែលចូលរួមចំណែកដំណាលគ្នា ឬមូលហេតុផ្សេងទៀតចំពោះការបាត់បង់ :

១. ការចូលរួមចំណែកបង្កឡើង ឬកើតឡើងដោយសារវិទ្យុសកម្មអ៊ីយ៉ុង ឬការបំពុលដោយសារសកម្មភាពវិទ្យុសកម្ម ដែលភាយចេញពីសំណល់នុយក្លេអ៊ែរ ឬពីចំហេះឥន្ធនៈនុយក្លេអ៊ែរ

២. សារធាតុវិទ្យុសកម្ម សារធាតុពុល សារធាតុផ្ទុះ ឬសារធាតុប្រកបដោយគ្រោះថ្នាក់ដទៃទៀត ឬការចម្លងរោគលើទ្រព្យសម្បត្តិ ដោយសារសកម្មភាពណាមួយនៃការតម្លើងនុយក្លេអ៊ែរ ឧបករណ៍ត្រួតពិនិត្យកម្តៅ ឬការតម្លើង នុយក្លេអ៊ែរផ្សេងទៀត ឬសារធាតុផ្សំនុយក្លេអ៊ែរដទៃទៀត ។

៣. សព្វាវុធសង្គ្រាមគ្រប់ប្រភេទទោះបីប្រើដោយការបំបែកអាតូម ឬការបំបែកសារធាតុនុយក្លេអ៊ែរ និង/ឬការរំលាយបញ្ចូលគ្នា ឬដោយប្រតិកម្មដទៃទៀត ឬដោយកំលាំងវិទ្យុសកម្ម ឬរូបធាតុវិទ្យុសកម្ម ។

## ២០. ករណីលើកលែងលើ រូបធាតុដែលដុតមិនឆេះ និងធន់នឹងប្រតិកម្មគីមី

នៅក្នុងផ្នែក "ការទទួលខុសត្រូវជាសាធារណៈ" នៃកិច្ចសន្យាធានារ៉ាប់រងនេះ លើកលែងរាល់បណ្តឹងទាមទារសំណងទាំងអស់ និងការបាត់បង់ដែលផ្អែកលេទោះបីដោយផ្ទាល់ ឬប្រយោលក្តី ដែលជាលទ្ធផលពី ឬជាប់ទាក់ទង ឬជាប់ពាក់ព័ន្ធនឹង :

១. រូបធាតុដែលដុតមិនឆេះ និងធន់នឹងប្រតិកម្មគីមី ឬ

២. ក្នុងករណីជាក់ស្តែង ឬដែលអះអាងថា រូបធាតុដែលដុតមិនឆេះ និងធន់នឹងប្រតិកម្មគីមីមានជាប់ទាក់ទងនឹងរបួស ឬការខូចខាតដែលជាប់ពាក់ពន្ធ័នឹងការប្រើប្រាស់ មានវត្តមាន មានអត្ថិភាព ការរកឃើញ ការយកចេញ ការកំចាត់ចោល ឬការជៀសវាងនូវរូបធាតុដែលដុតមិនឆេះ ការផ្សព្វផ្សាយ ឬអានុភាពនៃការផ្សព្វផ្សាយចំពោះរូបធាតុដែលដុតមិនឆេះ ទាំងឡាយ ឬរូបធាតុដែលធន់នឹងប្រតិកម្មគីមី ។

## ២១. កិច្ចសន្យាធានារ៉ាប់រងដែលគ្មានតម្លៃ

កិច្ចសន្យាធានារ៉ាប់រងនេះគឺគ្មានតម្លៃ។ បន្ទុកគឺត្រូវធ្លាក់លើបុគ្គលដែលត្រូវបានធានារ៉ាប់រង ក្នុងការផ្តល់ភស្តុតាងលើតម្លៃពិតប្រាកដ នៃទ្រព្យសម្បត្តិដែលត្រូវបានធានារ៉ាប់រងនៅពេលដែលមានការកើតឡើងនូវមហន្តរាយ ឬចំនួនពិតប្រាកដនៃការខូចខាតទាំងនោះ ។

## ២២. ខ ចែងស្តីអំពីករណីលើកលែងលើគ្រឹះនៃអគារ

ការធានារ៉ាប់រងលើអគារ ត្រូវបានលើកលែងចំពោះផ្នែកខាងក្រោមអគារណាមួយដែលស្ថិតនៅក្រោមផ្ទៃរាបស្មើនៃជាន់ដែលទាបជាងគេ (និងផ្នែកផ្សេងទៀតនៃគ្រឹះបេតុងសម្រាប់ដាក់ម៉ាស៊ីនដែលពង្រីកនៅពីលើផ្ទៃរាបស្មើទាំងនោះ) ។

## ២៣. ខ ចែងស្តីអំពីទ្រព្យសម្បត្តិជា គូ ឬ ឈុត

វាគឺជាការព្រមព្រៀងជាមុន និងប្រកាសអះអាងថា ថ្វីបើអ្វីៗគ្រប់ប្រភេទដែលមាននៅក្នុងកិច្ចសន្យាធានារ៉ាប់រងនេះមានលក្ខណៈផ្ទុយគ្នា ដែលទ្រព្យសម្បត្តិដែលត្រូវបានធានារ៉ាប់រងនីមួយៗមានលក្ខណៈជាគូ ឬឈុត នោះក្រុមហ៊ុនមិនមានកាតព្វកិច្ចទទួលខុសត្រូវ ក្នុងការធ្វើសំណងច្រើនជាងតម្លៃសមាមាត្រនៃផ្នែកពិសេសណាមួយ ឬផ្នែកផ្សេងៗទៀតនៃទ្រព្យសម្បត្តិដែលអាចត្រូវបានបាត់បង់ ដោយមិនគិតពីតម្លៃពិសេសណាមួយដែលទ្រព្យសម្បត្តិទាំងនោះអាចជាផ្នែកមួយនៃគូ ឬឈុតនោះ ។

រាល់លក្ខខណ្ឌ និង ខ ចែងទាំងអស់ត្រូវផ្អែកលើកិច្ចសន្យាធានារ៉ាប់រងនេះ ។

## ១. ខ ចែងស្តីអំពីអ្នកទទួលបញ្ចាំ (អ្នកទទួលសងបំណុល)

ប្រសិនបើមានករណីបាត់បង់កើតឡើង ការធ្វើសំណងត្រូវបង់ជូនអ្នកទទួលបញ្ចាំ (ម្ចាស់បំណុល) ដែលជាអ្នកទទួលផលប្រយោជន៍ស្របតាមកិច្ចសន្យាធានារ៉ាប់រងនេះ ដែលជាអត្ថប្រយោជន៍របស់អ្នកបញ្ចាំ (ម្ចាស់បំណុល) តែមួយគត់ដែលមានតម្លៃ ទោះបីជាសកម្មភាព ឬការធ្វេសប្រហែសណាមួយរបស់អ្នកបញ្ចាំ (កូនបំណុល) ឬម្ចាស់កម្មសិទ្ធិលើទ្រព្យសម្បត្តិ ឬបណ្តឹងរឹបអូសទ្រព្យសម្បត្តិណាមួយ ឬបណ្តឹងផ្លូវច្បាប់ណាមួយ ឬការជូនដំណឹងអំពីការលក់ដែលពាក់ព័ន្ធនឹង ទ្រព្យសម្បត្តិ ឬការប្រើប្រាស់បរិវេណអគារសម្រាប់គោលបំណងផ្សេងៗ ដែលមានហានិភ័យច្រើនជាងអ្វីដែលត្រូវបានអនុញ្ញាតដោយកិច្ចសន្យាធានារ៉ាប់រងនេះ ឬការមិនប្រើប្រាស់បរិវេណអគារ ឬដោយកត្តាផ្សេងទៀតដែលបង្កើននូវ ហានិភ័យដែលកើតឡើងចំពោះទ្រព្យសម្បត្តិដែលត្រូវបានធានារ៉ាប់រង ។ ដោយហេតុថាក្នុងករណីដែលអ្នកបញ្ចាំ (កូនបំណុល) ឬម្ចាស់កម្មសិទ្ធិខកខានក្នុងការបង់បុព្វលាភធានារ៉ាប់រងណាមួយ ដោយផ្អែកតាមកិច្ចសន្យាធានារ៉ាប់រងនេះ អ្នកទទួលបញ្ចាំ (ម្ចាស់បំណុល) នឹងតម្រូវអោយបង់នូវបុព្វលាភធានារ៉ាប់រងទាំងនោះ។ វាជាលក្ខខណ្ឌដែលថា អ្នកទទួលបញ្ចាំ (ម្ចាស់បំណុល)ត្រូវផ្តល់ព័ត៌មានដល់ក្រុមហ៊ុននូវការផ្លាស់ប្តូរកម្មសិទ្ធិ ឬមុខងាររបស់អគារ ឬអគារត្រូវបានទុកទំនេរចោល ឬការបង្កើននូវហានិភ័យដែលអ្នកទទួលបញ្ចាំ (ម្ចាស់បំណុល) ទាំងនោះគួរតែដឹង និងប្រសិនបើត្រូវបានអនុញ្ញាតដោយកិច្ចសន្យាធានារ៉ាប់រងនេះត្រូវបានកត់សម្គាល់ ហើយអ្នកទទួលបញ្ចាំ (ម្ចាស់បំណុល) ត្រូវតម្រូវអោយបង់បុព្វលាភធានារ៉ាប់រងសម្រាប់ការបង្កើននូវហានិភ័យទាំងនោះស្របតាមលក្ខខណ្ឌដែលមានចែងនៅក្នុងកិច្ចសន្យាធានារ៉ាប់រងនេះ បើមិនដូច្នេះទេ កិច្ចសន្យាធានារ៉ាប់រងនេះត្រូវចាត់ទុកជាមោឃៈ និងអសារបង់ ។
ហើយជាងនេះទៅទៀត វាជាការព្រមព្រៀងដែលថា នៅពេលណាមួយដែលក្រុមហ៊ុនធ្វើសំណងជូនអ្នកទទួលបញ្ចាំ (ម្ចាស់បំណុល) នូវចំនួនទឹកប្រាក់ណាមួយដែលមានការបាត់បង់ ឬខូចខាតស្របតាមកិច្ចសន្យាធានារ៉ាប់រងនេះ ព្រមទាំងមានការបញ្ជាក់អះអាងថាបានធ្វើសំណងជូនអ្នកបញ្ចាំ (កូនបំណុល) ឬម្ចាស់កម្មសិទ្ធិ នោះគ្មានការទទួលខុសត្រូវណាមួយផ្សេងទៀតត្រូវបានកើតឡើងឡើយ ហើយក្រុមហ៊ុនត្រូវបានផ្តល់សិទ្ធិស្របច្បាប់ទាំងអស់ក្នុងនាមអ្នកទទួលបញ្ចាំ (ម្ចាស់បំណុល) ដើម្បីទទួលបាននូវសំណងទាំងនោះមកវិញ ប៉ុន្តែមិនប៉ះពាល់ដល់សិទ្ធិរបស់អ្នកទទួលបញ្ចាំ (ម្ចាស់បំណុល) ក្នុងការទទួលបាននូវចំនួនទឹកប្រាក់សរុបទាំងអស់នៃការទាមទារសំណងណាមួយ ដែលអាចកើតឡើងចំពោះអ្នកបញ្ចាំ (កូនបំណុល) ទាំងនោះ ឬម្ចាស់កម្មសិទ្ធិ ឬភាគីណាមួយ ឬភាគីផ្សេងទៀតដែលត្រូវបានធានារ៉ាប់រងស្របតាមកិច្ចសន្យាធានារ៉ាប់រងនេះ ឬពីស្ថាប័នហិរញ្ញវត្ថុ ឬមូលនិធិណាមួយ ។

## ខ ចែងស្តីអំពីការមិនអនុញ្ញាតធ្វើមោឃភាពនៃកិច្ចសន្យាធានារ៉ាប់រងនេះ

នេះជាការព្រមព្រៀងដែលថា ការធ្វើមោឃភាពនៃកិច្ចសន្យាធានារ៉ាប់រងនេះ ដោយបុគ្គលដែលត្រូវបានធានារ៉ាប់រងនឹងមិនមានសុពលភាពឡើយ លើកលែងតែក្នុងករណីជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អ្នកទទួលបញ្ចាំ (ម្ចាស់បំណុល) ក្នុងរយៈពេល ១៤ថ្ងៃ តាមរយៈអាសយដ្ឋានដែលគេស្គាល់ចុងក្រោយ ។
ចំណាំ: នៅពេលដែលអ្នកទទួលផលប្រយោជន៍ ជាម្ចាស់បំណុល (Chargee) និងកូនបំណុល (Chargor) ពាក្យនៅក្នុង វង់ក្រចកត្រូវបានចាត់ទុកថាត្រូវបានជំនួសដោយពាក្យ អ្នកទទួលបញ្ចាំ និងអ្នកបញ្ចាំ ។

## ខ ចែងស្តីអំពីការដាក់កំហិតទណ្ឌកម្ម និងករណីលើកលែង (LMA 3100)

គ្មានក្រុមហ៊ុនធានារ៉ាប់រងណាមួយ អាចផ្តល់ការធានារ៉ាប់រង និងគ្មានក្រុមធានារ៉ាប់រងណាមួយ ទទួលខុសត្រូវចំពោះការបង់ជូននូវប្រាក់សំណងណាមួយឬអត្ថប្រយោជន៍ណាមួយ ដែលស្ថិតនៅក្នុងដែនកំណត់នៃបុរេលក្ខណខណ្ឌនៃការធានារ៉ាប់រងនោះបានឡើយដែលការបង់ជូនប្រាក់សំណងសម្រាប់បណ្តឹងទាមទារសំណងទាំងនោះនាំឱ្យក្រុមហ៊ុនធានារ៉ាប់រងនោះ ប្រឈមនឹងការដាក់ទណ្ឌកម្មណាមួយ ការហាមឃាត់ឬការដាក់កម្រិតដែលស្ថិតនៅក្រោមសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិ ឬការដាក់ទណ្ឌកម្ម ផ្នែកសេដ្ឋកិច្ច ឬពាណិជ្ជកម្ម ច្បាប់ ឬនិយតកម្មរបស់សហគមន៍អឺរ៉ុប ចក្រភពអង់គ្លេស ឬសហរដ្ឋអាមេរិច ។

ទំព័រនេះត្រូវបានទុកចោលដោយចេតនា